ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៦៧ សសរ.កសក

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានសម្របសម្រួល និងពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញសេចក្តីណែនាំលេខ០២ សណន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញសេចក្តីសម្រេចលេខ០៩៧ សសរ.កសក ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតក្រុមការងារ ដើម្បីសម្របសម្រួល និងអនុវត្តការពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់


អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
N° 200 Preah Norodom Blvd, Sangkat Tonle Bassak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

វិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានសម្របសម្រួល និងពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **គុយ ម៉ារិនឌី** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្តម **កៅ ផល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣-ឯកឧត្តម **ឃុន សាវឿន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤-លោក **ជា ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | ប្រធានប្រតិបត្តិ |
| ៥-លោក **ហាច ផា** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | អនុប្រធានប្រតិបត្តិ |
| ៦-លោក **ហេង ម៉ីនលី** | អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | អនុប្រធានប្រតិបត្តិ |
| ៧-លោក **គីម រ៉ាច័ន្ទ** | អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | ជំនួយការប្រធានលេខាធិការដ្ឋាន |
| ៨-លោក **ជា សុភ័ក្ត្រ** | ប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានកិច្ចការរដ្ឋបាល | ប្រធានផ្នែកកិច្ចការរដ្ឋបាល |
| ៩-លោក **ឈុប ថាវិត** | អនុប្រធានការិយាល័យផែនការ នៃនាយកដ្ឋានផែនការ និងស្ថិតិ | ប្រធានផ្នែកផែនការ និងគាំទ្រ កម្មវិធីកំណែទម្រង់ D & D |
| ១០-លោក **គន ជីវ័ន** | អនុប្រធានការិយាល័យរដ្ឋបាល ផែនការ និង សហប្រតិបត្តិការអន្តរជាតិ នៃមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | មន្ត្រីសម្របសម្រួល |
| ១១-លោក **ច័ន្ទ និត្យា** | មន្ត្រីនៃមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | មន្ត្រីសម្របសម្រួល |
| ១២-លោក **អ៊ុច ម៉េងហ៊ី** | មន្ត្រីនៃនាយកដ្ឋានកិច្ចការរដ្ឋបាល | មន្ត្រីសម្របសម្រួល |
| ១៣-លោក **ខ៊ែត ស៊ីណាង** | មន្ត្រីនៃនាយកដ្ឋានកិច្ចការរដ្ឋបាល | មន្ត្រីសម្របសម្រួល |
| ១៤-លោកស្រី **ខេង លីអ៊ីញ** | មន្ត្រីនៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | មន្ត្រីសម្របសម្រួល |
| ១៥-លោកស្រី **គាន់ បុប្ផា** | មន្ត្រីនៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | មន្ត្រីសម្របសម្រួល |
| ១៦-លោក **ប៉ុន គុម្ភៈ** | មន្ត្រីនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | មន្ត្រីសម្របសម្រួល |
| ១៧-លោកស្រី **គន ស្រីនាង** | មន្ត្រីនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | មន្ត្រីសម្របសម្រួល |
| ១៨-លោក **ស្តុង គា** | មន្ត្រីនៃនាយកដ្ឋានផែនការ និងស្ថិតិ | មន្ត្រីសម្របសម្រួល |
| ១៩-លោក **ផាន់ សុផានិត** | មន្ត្រីនៃនាយកដ្ឋានផែនការ និងស្ថិតិ | មន្ត្រីសម្របសម្រួល។ |

**ប្រការ២.-**

លេខាធិការដ្ឋានសម្របសម្រួល និងពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចដំណើរការនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង
- សម្របសម្រួល និងគាំទ្រដល់អង្គភាពក្រោមឱវាទក្នុងការអនុវត្តសកម្មភាពកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង
-សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬកិច្ចការជាអាទិភាពរបស់ក្រសួង
- សម្របសម្រួល និងរៀបចំលើកផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ វិស័យកសិកម្ម ដោយដាក់បញ្ចូលទៅក្នុងគម្រោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រសួង ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីពិនិត្យ និងសម្រេច

- រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការគ្រប់គ្រង ការតាមដាន និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងជូនថ្នាក់ដឹកនាំក្រសួង

- រៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- សម្របសម្រួល និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្របតាមសេចក្ដីសម្រេចរួមដែលបានឯកភាពគ្នារវាងក្រសួងជាមួយនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្រោមថ្នាក់ជាតិ(គ.ជ.អ.ប) ស្ដីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប

- ត្រូវមានការប្រជុំជាទៀងទាត់០១ខែម្ដង និងកោះប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង។

**ប្រការ៣**.

លេខាធិការដ្ឋាននេះមានជំនួយការ និងផ្នែកចំនួន០២ ដើម្បីជួយសម្របសម្រួល និងប្រាស្រ័យទាក់ទងជាប្រចាំជាមួយបណ្ដាអង្គភាពក្រោមឱវាទក្រសួង ដែលមានភារកិច្ចដូចខាងក្រោម ៖

១. ជំនួយការប្រធានលេខាធិការដ្ឋាន មានភារកិច្ច ៖

- សម្របសម្រួល និងទំនាក់ទំនងជាមួយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

- តាមដានកិច្ចការរដ្ឋបាលទូទៅដែលបម្រើដល់ការអនុវត្តកម្មវិធីកំណែទម្រង់ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យកសិកម្ម

- សម្របសម្រួល សហការ និងធ្វើការទំនាក់ទំនងជាប្រចាំជាមួយអង្គភាពក្រោមឱវាទក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងផ្នែកនានានៃលេខាធិការដ្ឋាន

- គ្រប់គ្រង តាមដាន និងផ្ដល់សេវាគាំទ្រផ្នែកថវិកា និងរដ្ឋបាលរបស់លេខាធិការដ្ឋាន

- សហការរៀបចំរបៀបវារៈ និងខ្លឹមសារសម្រាប់កិច្ចប្រជុំនានា

- ពិនិត្យ និងផ្ដល់យោបល់លើឯកសារ និងរបាយការណ៍នានា ដែលត្រូវដាក់ជូនថ្នាក់ដឹកនាំលេខាធិការដ្ឋានពិនិត្យ និងសម្រេច

- ពិនិត្យលើការរៀបចំឯកសារ របាយការណ៍ និងកំណត់ហេតុកិច្ចប្រជុំនានាជូនថ្នាក់ដឹកនាំលេខាធិការដ្ឋាន

- រៀបចំកាលវិភាគ និងការណាត់ជួបពិភាក្សាការងារនានារបស់ថ្នាក់ដឹកនាំលេខាធិការដ្ឋាន

- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់ប្រធានលេខាធិការដ្ឋាន។

២. ផ្នែកគាំទ្រកិច្ចការរដ្ឋបាល មានភារកិច្ច៖

- អនុវត្តការងាររដ្ឋបាលប្រចាំថ្ងៃ

- រៀបចំលិខិតរដ្ឋបាល និងលិខិតស្នាមផ្សេងៗ

- គ្រប់គ្រងឯកសាររដ្ឋបាលរបស់លេខាធិការដ្ឋាន

- ធ្វើកំណត់ហេតុរាល់កិច្ចការប្រជុំ និងរបាយការណ៍ផ្សេងៗ

- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់ប្រធានលេខាធិការដ្ឋាន។

៣. ផ្នែកផែនការ និងគាំទ្រកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានភារកិច្ច ៖

- សម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាមួយ គ.ជ.អ.ប

- សហការជាមួយអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីផ្ដល់ការគាំទ្រដល់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំបែបបទសម្រាប់ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជូនលេខាធិការដ្ឋាន

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ សម្រាប់គាំទ្រដល់ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងជូនថ្នាក់ដឹកនាំលេខាធិការដ្ឋាន ពិនិត្យ និងសម្រេច

- សម្របសម្រួល តាមដាន និងរាយការណ៍អំពីការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង

- ផ្ដល់ទំនាក់ទំនង និងគាំទ្រផ្នែកបច្ចេកទេសដល់អង្គភាពចំណុះក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត

- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់ប្រធានលេខាធិការដ្ឋាន។

**ប្រការ៤.-**

ត្រូវបានបង្កើតជនបង្គោលតាមបណ្ដាអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជួយសម្របសម្រួល និងទំនាក់ទំនងក្នុងការពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាមួយលេខាធិការដ្ឋាន ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-លោក **សន សុធី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម នៃអគ្គនាយកដ្ឋានកៅស៊ូ |
| ២-លោក **ជៀម ឡឺង** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងនីតិកម្ម នៃរដ្ឋបាលជលផល |
| ៣-លោក **សេង ស៊ីនណារុន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ នៃរដ្ឋបាលព្រៃឈើ |
| ៤-លោក **អ៊ុក គុណា** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានកសិកម្ម |
| ៥-លោក **ពេជ្រ រ៉េដា** | អនុប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| ៦-លោក **អ៊ិល ឧត្តី** | អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ |
| ៧-លោក **ជី សុមិន្ធា** | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ |
| ៨-លោក **វ៉ុត្រ ចិចិត្រ** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម |
| ៩-លោកស្រី **សាយ ខ៊ាន់ដែន** | អនុប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម |
| ១០-លោក **ពេជ សម្បត្តិ** | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១១-លោកស្រី **ហួរ មុន្នីវា** | អនុប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម |
| ១២-លោក **ខែម ស៊ីណាត** | ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក នៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស។ |

**ប្រការ៥.-**

សេចក្ដីសម្រេចលេខ០៩៧ សសរ.កសក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ.ជ.អ.ប
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ